# ទស្សនាវដ្តី
# Magazine

## គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
## Cambodia National Mekong Committee

លេខ១ ត្រីមាសទី២ ឆ្នាំ២០១៤

Issue No.1 Quarter 2, 2014




**ប្រមុខរដ្ឋាភិបាលនៃប្រទេសជាសមាជិកក្នុងកិច្ចប្រជុំកំពូលលើកទី២របស់ គណៈកម្មការទន្លេមេគង្គ នៅទីក្រុងហូជីមិញ ប្រទេសវៀតណាម នាថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៤**

**Heads of Riparian Governments in the 2nd MRC Summit, Ho Chi Minh City, Viet Nam on 5 April 2014**

**មាតិកា** (Content) ទំព័រ(Page)

អារម្ភកថា (Foreword)........................................ ii

I. សកម្មភាពសំខាន់ៗ (Key activities)........................................ ១

II. សកម្មភាពអនុវត្តគម្រោង និងកម្មវិធីនានា (Implementation of projects and programmes)........................................៩

III. ឯកសារបោះពុម្ពរបស់គណៈកម្មការទន្លេមេគង្គ (Publications of the Mekong River Commission) ................២៤

## សមាសភាពក្រុមការងារ

១. ឯកឧត្តម វ៉ាត់ បុត្តកុសល អគ្គលេខាធិការរង គ.ជ.ទ.ម.ក. ជា ប្រធាន

២. លោក ហាក់ សុជាតិ ប្រធាននាយកដ្ឋានផែនការ និងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិក

៣. លោក អ៊ូ សុផាណា ប្រធាននាយកដ្ឋានរដ្ឋបាល-ហិរញ្ញវត្ថុ ជាសមាជិក

៤. លោក ប៊ុល ដែលលី លេខាធិការនៃលេខាធិការដ្ឋានបបនីយជីវមណ្ឌលបឹងទន្លេសាប ជាសមាជិក

៥. លោក ឈាង ហុង ប្រធាននាយកដ្ឋានគ្រប់គ្រងព័ត៌មាន និងចំណេះដឹង ជាសមាជិក

ក្រុមការងារសូមថ្លែងអំណរគុណចំពោះឯកឧត្តម តែ ណាវុធ អគ្គលេខាធិការ គ.ជ.ទ.ម.ក.ដែលបានគាំទ្រ និងណែនាំបន្ថែមដល់ក្រុមការងារ និងសូមអគុណ ឯកឧត្តម អគ្គលេខាធិការរង លោក លោកស្រី ជាប្រធាន អនុប្រធាននាយកដ្ឋាន មន្ត្រីសម្របសម្រួលទទួលបន្ទុកគម្រោងកម្មវិធីនិងជំនាញការជាតិទាំងអស់ដែលបានសហការជួយផ្ដល់ព័ត៌មានសម្រាប់ការចុះផ្សាយក្នុងទស្សនាវដ្ដីនេះ។

## Member of Working Group

1. H.E Mr. Watt Botkosal, Deputy Secretary General, Chair
2. Mr. Hak Socheat, Director, Department of Planning and International Cooperation, Member
3. Mr. Ou Sophanna, Director, Administration and Finance Department, Member
4. Mr. Bul Delly, Secretary, Tonle Sap Lake Biosphere Reserve Secretariat, Member
5. Mr. Chheang Hong, Director of Information and Knowledge Management Department, Member

The Working Group would like to thank H.E Mr. TE NAVUTH, Secretary General of CNMC for his support and advice to the group and my thanks go to excellencies Deputy Secretaries General, all Directors/Deputy Directors, National Coordinators and consultants for projects and programmes for their cooperation and inputs for the magazine.

# អារម្ភកថា

គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា (គ.ជ.ទ.ម.ក) ជាសេនាធិការរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់សម្របសម្រួលក្នុងការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គ។ គ.ជ.ទ.ម.ក.ក៏ដូចជាគណៈកម្មាធិការជាតិទន្លេមេគង្គនៃប្រទេសជាសមាជិកផ្សេងទៀតដែរ គឺមានតួនាទីក្នុងការសម្របសម្រួលក្នុងក្របខ័ណ្ឌនៃប្រទេសរៀងៗខ្លួន ក្នុងការអនុវត្តឲ្យមានប្រសិទ្ធភាពនិងប្រកបដោយជោគជ័យនូវកិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥ និងនីតិវិធីស្តីពីការប្រើប្រាស់ទឹករបស់គណៈកម្មការទន្លេមេគង្គ (MRC) និងក្នុងការអនុវត្តផែនការយុទ្ធសាស្ត្ររបស់ MRC យុទ្ធសាស្ត្រអភិវឌ្ឍន៍អាងដោយផ្អែកលើគោលការណ៍នៃការគ្រប់គ្រងធនធានទឹកចម្រុះ វិមជ្ឈការ មុខងារស្នូលនៃការគ្រប់គ្រងអាងទន្លេនិងបណ្តាគម្រោង កម្មវិធីកិច្ចសហប្រតិបត្តិការតំបន់សម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៃអាងទន្លេមេគង្គ។

កិច្ចប្រជុំកំពូលលើកទី២របស់គណៈកម្មការទន្លេមេគង្គបានប្រព្រឹត្តទៅនាថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៤ នៅទីក្រុងហូជីមិញ ប្រទេសវៀតណាម ដោយមានការអញ្ជើញចូលរួមពីប្រមុខរដ្ឋាភិបាល នៃប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ រួមមាន កម្ពុជា ឡាវ និងវៀតណាម និងបេសកជនពិសេស តំណាងនាយករដ្ឋមន្ត្រីថៃ គណៈប្រតិភូនៃដៃគូសន្ទនា (ចិននិងមីយ៉ាន់ម៉ា) គណៈប្រតិភូនៃដៃគូអភិវឌ្ឍន៍ គណៈប្រតិភូនៃស្ថាប័នហិរញ្ញវត្ថុ និងគណៈប្រតិភូនៃអង្គការតំបន់ និងអន្តរជាតិ។

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមនិងដឹកនាំគណៈប្រតិភូជាន់ខ្ពស់រាជរដ្ឋាភិបាលកម្ពុជា។ សេចក្តីថ្លែងការណ៍កិច្ចប្រជុំកំពូលលើកទី២ របស់គណៈកម្មការទន្លេមេគង្គបានបង្ហាញអំពីការប្តេជ្ញាចិត្តយ៉ាងមោះមុតរបស់រដ្ឋាភិបាល នៃបណ្តាប្រទេសជាសមាជិកក្នុងការអនុវត្តកិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

ទស្សនាវដ្តីរបស់គ.ជ.ទ.ម.ក បានបង្ហាញអំពីសកម្មភាពសំខាន់ៗ ការងារសម្របសម្រួល ការអនុវត្តបណ្តាគម្រោង កម្មវិធីសម្រេចបាននូវសមិទ្ធផលជាទីមោទនៈ ដែលក្នុងនោះទាំងការងារបច្ចេកទេស និងកិច្ចសហប្រតិបត្តិការក្នុងកម្រិតជាតិ និងតំបន់។ គ.ជ.ទ.ម.ក នៅមានភាពប្រឈមជាច្រើន ដើម្បីធានានូវប្រសិទ្ធភាពនៃការងាររបស់ខ្លួនតាមរយៈការពង្រឹងកិច្ចសហប្រតិបត្តិការកាន់តែជិតស្និទ្ធជាមួយបណ្តាក្រសួង ស្ថាប័ន ជាសមាជិក និងជាមួយបណ្តាគណៈកម្មាធិការជាតិទន្លេមេគង្គនៃប្រទេសជាសមាជិក។

ខ្ញុំសូមវាយតម្លៃខ្ពស់ជាមួយនិងការកោតសរសើរដោយស្មោះចំពោះបណ្តាសកម្មភាពនិងសមិទ្ធផលនៃការងារដែលសម្រេចបានបណ្តាក្នុងឆ្នាំកន្លងមកដែលពិតជាបានបង្ហាញពីការខិតខំយកចិត្តទុកដាក់អនុវត្តការងាររបស់មន្ត្រី និងបុគ្គលិកទាំងអស់របស់ គ. ជ.ទ.ម.ក និងក្រសួងស្ថាប័នដែលជាសមាជិក។

ឯកឧត្តម **លឹម គានហោ**
រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម
ប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

# Foreword

Cambodia National Mekong Committee (CNMC) is the Government Institution for coordinating the management, protection, conservation and development of water and related resources in the Mekong Basin. CNMC as other National Mekong Committee of member countries has role to coordinate within the national framework of the respective country in effective and successful implementation of the 1995 Mekong Agreement and MRC Procedures on the use of water of the Mekong River and implementation of MRC Strategic Plan, the IWRM-based Basin Development Strategy, Decentralization and Core Function process and implementation of project and programmes for regional cooperation for the sustainable development of the Mekong River Basin.

The 2nd MRC Summit was held on 5 April 2014 in Ho Chi Minh City, Viet Nam, attended by Heads of the MRC member countries, Cambodia, Lao PDR and Vietnam and Special Envoy representing the Prime Minister of Thailand, delegation of dialogue partners (China and Myanmar), the delegation of the development partners, the delegation of the regional and international institutions.

Samdech Akka Moha Sena Padei Techo HUN SEN, Prime Minister of the Kingdom of Cambodia, attended and led High level Government Delegation. The Declaration of the 2nd MRC Summit shows the sharp commitment of the Governments of the member countries in the effective implementation of the 1995 Mekong Agreement.

CNMC Magazine shows the key activities, coordination for projects and programmes implementation proudly achieved including technical affairs and cooperation at the national and regional levels. However CNMC still faces many challenges to ensure the effectiveness of its work by strengthening close cooperation with line ministries and agencies and with the National Mekong Committees of the member countries.

I highly appreciate and inspire the activities and achievements of the work achieved in the past years which have shown striving efforts by all officials and staff of CNMC and line ministries.

H.E Mr. LIM KEAN HOR
Minister of Water Resources and Meteorology,
Chairman of Cambodia National Mekong Committee


អារម្ភកថា (Forword)

# I. សកម្មភាពសំខាន់ៗ (Key Activities)



កិច្ចប្រជុំកំពូលលើកទី២ របស់គណៈកម្មការទន្លេមេគង្គនៅទីក្រុងហូជីមិញ ប្រទេសវៀតណាម នាថ្ងៃទី៥ ខែមេសា ឆ្នាំ ២០១៤ (2nd MRC Summit, Ho Chi Minh City, Viet Nam, 5 April 2014)




សន្និសីទអន្តរជាតិមុនកិច្ចប្រជុំកំពូល ស្តីពីកិច្ចសហប្រតិបត្តិការដើម្បីទឹក ថាមពល និងសន្តិសុខស្បៀង ក្រោមបរិបទបម្រែបម្រួលអាកាសធាតុក្នុងអាងទន្លេមេគង្គ នាថ្ងៃទី២-៣ ខែមេសា ឆ្នាំ២០១៤ (Pre-Summit International Conference on Cooperation for Water, Energy and Food Security under climate change context in the Mekong River Basin, 2-3 April 2014)




សកម្មភាពសំខាន់ៗរបស់ក្រុមប្រឹក្សានៃគណៈកម្មការទន្លេមេគង្គ ( Key activities of MRC Council)



សកម្មភាពសំខាន់ៗរបស់គណៈកម្មាធិការរួមនៃគណៈកម្មការទន្លេមេគង្គ ( Key activities of MRC Joint Committee )



កិច្ចប្រជុំលើកទី១០នៃក្រុមការងារជំនាញចម្រុះកម្ពុជា-វៀតណាមអំពីការរៀបចំសេចក្តីព្រាងបទបញ្ញត្តិស្តីពីការប្រើប្រាស់ធនធានទឹកតាមបណ្តោយព្រំដែនកម្ពុជា- វៀតណាម នាថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ ទីក្រុងសៀមរាប (The 10th Joint Expert Group Meeting of Cambodia - Vietnam on the Draft Regulations on the use of water resources along the border of Cambodia - Vietnam,13 June 2014 Siem Reap, Cambodia.)

# កិច្ចប្រជុំកំពូលលើកទី២របស់គណៈកម្មការទន្លេមេគង្គ នៅទីក្រុងហូជីមិញ ប្រទេសវៀតណាម នាថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៤

# 2nd MRC Summit, Hochi Minh City, Viet Nam, 5 April 2014





កិច្ចប្រជុំកំពូលនេះ មានការអញ្ជើញចូលរួមពីប្រមុខរដ្ឋាភិបាលនៃប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គកម្ពុជា ឡាវ និងវៀតណាម និងបេសកជនពិសេសតំណាងនាយករដ្ឋមន្ត្រីថៃ គណៈប្រតិភូ នៃដៃគូសន្ទនា (ចិន ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងធនធានទឹក និងមីយ៉ានម៉ា ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងការបរទេស) គណៈប្រតិភូនៃដៃគូអភិវឌ្ឍន៍ គណៈប្រតិភូនៃស្ថាប័នហិរញ្ញវត្ថុ និងគណៈប្រតិភូនៃអង្គការតំបន់និងអន្តរជាតិ។

គណៈប្រតិភូជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជាដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា អមដំណើរដោយឯកឧត្តម **លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម និងជាប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងជាសមាជិកក្រុមប្រឹក្សាគណៈកម្មការទន្លេមេគង្គតំណាងកម្ពុជា និងរដ្ឋមន្ត្រី រដ្ឋលេខាធិការនៃ រាជរដ្ឋាភិបាល ព្រមទាំងមន្ត្រីជាន់ខ្ពស់មួយចំនួនទៀត៕




សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

Samdech Akka Moha Sena Padei Techo HUN SEN Prime Minister of Kingdom of Cambodia

The Summit was attended by Heads of the MRC member countries, Cambodia, Lao PDR and Vietnam and Special Envoy representing the Prime Minister of Thailand, delegation of dialogue partners (China, led by the Minister of Water Resources, Myanmar, led by Minister of Foreign Affairs), the delegation of the development partners, the delegation of the regional and international institutions.

High level Government Delegation of the Kingdom of Cambodia led by Samdech Akka Moha Sena Padei Techo HUN SEN, Prime Minister of the Kingdom of Cambodia, accompanied by H.E Mr. LIM KEAN HOR, Minister of Water Resources and Meteorology, and Chairman of the Cambodian National Mekong Committee and MRC Council Member for Cambodia and other Ministers, Secretaries of State, and senior officials.

## សកម្មភាពអ្នកចូលរួមក្នុងកិច្ចប្រជុំកំពូល (Summit participants’ activities)



សេចក្ដីថ្លែងការណ៍នៃកិច្ចប្រជុំកំពូលលើកទី២របស់គណៈកម្មការទន្លេមេគង្គ បង្ហាញពីការប្ដេជ្ញាចិត្តដ៏មោះមុតរបស់រដ្ឋាភិបាល នៃប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ រួមមានប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម បានរំលឹកឡើងវិញពីការប្ដេជ្ញាចិត្ត ដែលបានកំណត់កាលពី៤ឆ្នាំមុនក្នុងកិច្ចប្រជុំកំពូលលើកទី១របស់ខ្លួនស្ដីពី បញ្ហាចំពោះមុខជាគន្លឹះសម្រាប់អាងទន្លេមេគង្គនិងគណៈកម្មការទន្លេមេគង្គ និងមធ្យោបាយដើម្បីដោះស្រាយបញ្ហាទាំងនោះ។

ប្រមុខរដ្ឋាភិបាល នៃប្រទេសសមាជិកគណៈកម្មការទន្លេមេគង្គបានពិភាក្សាក្នុងចំណោមវិស័យជាអាទិភាព និងមធ្យោបាយ ដែលគណៈកម្មការទន្លេមេគង្គអាចលើកកម្ពស់ប្រសិទ្ធភាពនិងភាពជាម្ចាស់របស់ខ្លួនដោយប្រទេសជាសមាជិកនៅឆ្នាំ២០៣០ និងការពង្រឹងឡើងវិញនូវកិច្ចសហប្រតិបត្តិការនៅក្នុងតំបន់ក្នុងការគ្រប់គ្រងទឹក និងធនធានពាក់ព័ន្ធឆ្លងដែននាំឆ្ពោះទៅមុខ នៃការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាននៅឆ្នាំ ២០១៥៕




The Summit declaretion shows the strong commitment of the Government of the member countries for effective implementation of the 1995 Mekong Agreement. The Second MRC Summit was the most important event as Heads of the MRC Countries, Cambodia, Lao PDR, Thailand and Viet Nam revisited their commitments made four years ago at the 1st Summit on a number of key issues facing the Mekong Basin and the MRC and agree on best ways to address those issues.

Heads of the MRC Countries further discussed, amongst other key priority areas, the best ways in which the MRC can promote its effectiveness and ownership by Member Countries by 2030 and reinvigorate regional cooperation in the transboundary management of water and related resources ahead of the establishment of an ASEAN economic community by 2015.

# សន្និសីទអន្តរជាតិមុនកិច្ចប្រជុំកំពូលស្តីពីកិច្ចសហប្រតិបត្តិការដើម្បីទឹក ថាមពល និងសន្តិសុខស្បៀងក្រោមបរិបទការប្រែប្រួលអាកាសធាតុក្នុងអាងទន្លេមេគង្គ

# Pre-summit International Conference on Cooperation for Water, Energy and Food Security under climate change context in the Mekong River Basin

សន្និសីទអន្តរជាតិស្តីពី កិច្ចសហប្រតិបត្តិការ ដើម្បីទឹក ថាមពល និងសន្តិសុខស្បៀង ក្រោមបរិបទបម្រែបម្រួលអាកាសធាតុ ក្នុងអាងទន្លេមេគង្គត្រូវបានរៀបចំឡើង ដោយគណៈកម្មការទន្លេមេគង្គ នាថ្ងៃទី០២-០៣ ខែមេសា ឆ្នាំ ២០១៤ នៅទីក្រុងហូជីមិញ ប្រទេសវៀតណាម ដើម្បីត្រៀមលក្ខណៈនិងអបអរសាទរដល់កិច្ចប្រជុំកំពូលលើកទី២ របស់គណៈកម្មការទន្លេមេគង្គ ដែលរៀបចំឡើងនាថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៤។ សន្និសីទនេះ បានពិភាក្សាគ្នាអំពីបញ្ហាសហប្រតិបត្តិការអន្តរជាតិ និងតំបន់ពាក់ព័ន្ធ ជាមួយនឹងការផ្តោតអារម្មណ៍លើបញ្ហាប្រឈមនានារវាងទឹកថាមពល និងស្បៀងស្ថិតនៅក្រោមការផ្លាស់ប្តូរអាកាសធាតុក្នុងអាងទន្លេឆ្លងដែន។

International Conference on Cooperation for Water, Energy and Food Security under climate change context in the Mekong River Basin was organized by the Mekong River Commission on 02-03 April, 2014 at the Ho Chi Minh City, Viet Nam to congratulate the 2nd MRC Summit being organized on 04-05 April 2014. There is a discussion about the international and regional cooperation issues which focused on the challenges between water, energy and food in the context of climate change in tranboundary basin.






ឯកឧត្តម តែ ណាវុធ អគ្គលេខាធិការគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ដឹកនាំវគ្គពិភាក្សានៃអង្គសន្និសីទ

H.E Mr. TE NAVUTH Secretary General, CNMC Chairs the session







សកម្មភាពចូលរួមក្នុងអង្គសន្និសីទ

Conference participants' activities

# សកម្មភាពសំខាន់ៗរបស់ក្រុមប្រឹក្សាគណៈកម្មការទន្លេមេគង្គ
## Key Activities of Mekong River Commission Council




ឯកឧត្តម **លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ប្រធាន គ.ជ.ទ.ម.ក.សមាជិកក្រុមប្រឹក្សា MRC តំណាងកម្ពុជា និងជាប្រធានក្រុមប្រឹក្សា MRC សម្រាប់ឆ្នាំ ២០១១-២០១២ ក្នុងអង្គប្រជុំក្រុមប្រឹក្សាលើកទី១៧ នាថ្ងៃទី ២៦ ខែមករា ឆ្នាំ២០១១ នៅទីក្រុងហូជីមិញ វៀតណាម និងការចុះហត្ថលេខាលើនិតិវិធីស្តីពីគុណភាពទឹក។

H.E. Mr. LIM KEAN HOR, Minister of Water Resources and Meteorology of Cambodia, Chairperson of the Cambodia National Mekong Committee, Member of the MRC Council for Cambodia, Chairperson of the MRC Council for 2011/2012 expresses his statement in the 17th MRC Council Meeting, 26 January 2011, Ho Chi Minh, Viet Nam for the signing of Procedures on Water Quality.



កិច្ចប្រជុំនេះបានអញ្ជើញចូលរួមដោយ គណៈប្រតិភូនៃប្រទេសជាសមាជិករួមមាន កម្ពុជា ឡាវ ថៃ និង វៀតណាម តំណាងដៃគូអភិវឌ្ឍន៍នានា និងមន្ត្រីលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ។

គណៈប្រតិភូកម្ពុជាដឹកនាំដោយឯកឧត្តម **លឹម គានហោ** អមដំណើរ ដោយសមាជិកប្រតិភូ រួមមានមន្ត្រីតំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា។

The Meeting was attended by Delegations of the member countries, including Cambodia, Lao PDR, Thailand and Vietnam, representatives of development partners and the MRC Secretariat.

Cambodian Delegation led by H.E Mr. LIM KEAN HOR accompanied by Delegation Members representatives of Ministry of Foreign Affairs and International Cooperation and General Secretariat of Cambodia National Mekong Committee.

ក្រុមប្រឹក្សានៃគណៈកម្មការទន្លេមេគង្គបានបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តរបស់ពួកគេតាមរយៈការអនុម័ត និងការចុះហត្ថលេខាលើនីតិវិធីស្តីពីគុណភាពទឹករបស់គណៈកម្មការទន្លេមេគង្គ។ សមាជិកក្រុមប្រឹក្សាទាំងអស់បានបញ្ជាក់ថា នីតិវិធីនេះ គឺជាឯកសារសំខាន់ណាស់ហើយការមូលមតិគ្នារបស់ពួកគេអំពីតម្រូវការ ដើម្បីរក្សាបាននូវគុណភាពទឹកល្អនៅក្នុងទន្លេមេគង្គក្នុងគ្រាមានការកើនឡើង ការអភិវឌ្ឍឆ្ពោះទៅរកនិរន្តរភាពនៅក្នុងអាងទន្លេនិងការការពារធនធានធម្មជាតិ។ ការណ៍នេះធានាថា គុណភាពទឹកនៅតែល្អសម្រាប់មនុស្សជំនាន់ក្រោយ ហើយថានៅក្នុងព្រឹត្តិការណ៍ នៃការប្រកាសអាសន្នសម្រាប់បរិស្ថាន ប្រទេសជាសមាជិកត្រូវបានរៀបចំ ដើម្បីជួយគ្នាទៅវិញទៅមកជាមួយនឹងការឆ្លើយតបបន្ទាន់សម្រាប់នីតិវិធីដើម្បីការពារសហគមន៍រស់នៅតាមដងទន្លេនិងបរិស្ថានទន្លេមេគង្គ។

The Council of the MRC reaffirm their highest commitment through the approval and signing of the MRC Procedures for Water Quality. All council members expressed that the Procedures is extremely important document, and their consensus about the need to maintain good water quality in the Mekong River amid the increasing development toward sustainability in the basin and protection of the natural resources. This assures that water quality remains good for future generations and that in the event of an environmental emergency, Member Countries are prepared to assist one another with emergency response Procedures to protect riverine communities and the Mekong River's environment.




សកម្មភាពសំខាន់ៗ (Key activities)

# កិច្ចប្រជុំក្រុមប្រឹក្សាគណៈកម្មការទន្លេមេគង្គលើកទី១៨ នៅទីក្រុងសៀមរាប កម្ពុជា នាថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១១

## The 18th MRC Council Meeting, Siem Reap, Cambodia, 09 December 2011




ឯកឧត្តមបណ្ឌិត **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រីនិងជាតំណាងដ៏ខ្ពង់ខ្ពស់សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានអញ្ជើញចូលរួមជាគណៈអធិបតីនិងថ្លែងស្វាគមន៍ក្នុងពិធីបើកកិច្ចប្រជុំ។

H.E Dr.YIM CHHAY LY, Deputy Prime Minister, senior representative of Samdech Techo Hun Sen, Prime Minister of the Kingdom of Cambodia, attends and delivers his welcome speech at the Council Meeting.




ឯកឧត្តម **លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម ប្រធាន គ.ជ.ទ.ម.ក. សមាជិកក្រុមប្រឹក្សា MRC តំណាងកម្ពុជា និងជាប្រធានក្រុមប្រឹក្សា MRC សម្រាប់ឆ្នាំ ២០១១ - ២០១២ ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាលើកទី១៨។

H.E.Mr. LIM KEAN HOR, Minister of Water Resources and Meteorology of Cambodia, Chairperson of the Cambodia National Mekong Committee, Member of the MRC Council for Cambodia, Chairperson of the MRC Council for 2011/2012, chairs the 18th MRC Council Meeting.








សកម្មភាព និងដំណើរការនៃអង្គប្រជុំ
Meeting Progress and activities

# សកម្មភាពសំខាន់ៗរបស់គណៈកម្មាធិការរួមនៃគណៈកម្មការទន្លេមេគង្គ

## Key Activities of the MRC Joint Committee









**ឯកឧត្ដម ស៊ិន នីនី** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ទ.ម.ក. សមាជិកបម្រុងនៃក្រុមប្រឹក្សា MRC តំណាងកម្ពុជា ថ្លែងស្វាគមន៍ កិច្ចប្រជុំគណៈកម្មាធិការរួម MRC លើកទី៣៣ នាថ្ងៃទី២៥-២៦ ខែមីនា ឆ្នាំ២០១១ នៅក្រុងព្រះសីហនុ កម្ពុជា

H.E. Mr. SIN NINY Permanent Vice-Chairman of CNMC, Alternate Member of the MRC Council for Cambodia, expresses his welcome statement in the 33rd MRC JC Meeting, 25-26 March 2011, Preah Sihanouk Ville, Cambodia.

ឯកឧត្ដម **តែ ណាវុធ** អគ្គលេខាធិការ គ.ជ.ទ.ម.ក. សមាជិកនៃគណៈកម្មាធិការរួម MRC តំណាងកម្ពុជា ដឹកនាំប្រតិភូកម្ពុជា ចូលរួមកិច្ចប្រជុំគណៈកម្មាធិការរួម MRC

H.E. Mr. TE NAVUTH Secretary General of CNMC, Member of the MRC JC for Cambodia, leads Cambodia Delegation for MRC JC Meeting






# កិច្ចប្រជុំលើកទី១០ នៃក្រុមការងារជំនាញចម្រុះ កម្ពុជា-វៀតណាម អំពីការរៀបចំសេចក្តីព្រាងបទបញ្ញត្តិស្តីពីការប្រើប្រាស់ធនធានទឹកតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម

## The 10th JEG Meeting of Cambodia - Vietnam on the Draft Regulations on the use of water resources along the border of Cambodia - Viet Nam

គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា បានសម្របសម្រួលការរៀបចំកិច្ចប្រជុំលើកទី១០ នៃក្រុមការងារជំនាញចម្រុះកម្ពុជា-វៀតណាម អំពីការរៀបចំសេចក្តីព្រាងបទបញ្ញត្តិស្តីពីការប្រើប្រាស់ធនធានទឹកតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម នាថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០១៤ នៅសាលប្រជុំសណ្ឋាគារអង្គរប៉ារ៉ាឌីទីរួមខេត្តសៀមរាប។ កិច្ចប្រជុំនេះបានប្រព្រឹត្តទៅក្រោមអធិបតីភាព លោក មី លីហួត អគ្គនាយករងរដ្ឋបាល និងជាប្រធានក្រុមការងារជំនាញចម្រុះកម្ពុជា ក្រសួងធនធានទឹក និងឧតុនិយម លោកបណ្ឌិត Le Duc Trung អគ្គនាយក គណៈកម្មាធិការជាតិទន្លេមេគង្គវៀតណាម និងជាប្រធានក្រុមការងារជំនាញចម្រុះវៀតណាម។ អញ្ជើញចូលរួមមានមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងមន្ទីរធនធានទឹកឧតុនិយម ខេត្តរតនគីរី តាកែវ ស្វាយរៀង និងព្រៃវែង ក្រសួងធនធាន ធម្មជាតិ និងបរិស្ថាន គណៈកម្មាធិការជាតិទន្លេមេគង្គនៃប្រទេសទាំងពីរ និងមន្ត្រីតំណាងលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ៕

Cambodia National Mekong Committee facilitated the 10th JEG Meeting of Cambodia - Vietnam on the Draft Regulations on the use of water resources along the border of Cambodia - Viet Nam on 13 June 2014 in Siem Reap, Angkor Paradise Hotel.

The Meeting was co-chaired by Mr. Mey Li Huoth, Deputy Director General of Administration Affairs and Chairman of the Joint Expert Group for Cambodia, Ministry of Water Resources and Meteorology and Dr. Le Duc Trung, General Director of Viet Nam National Mekong Committee, Ministry of Natural Resources and Environment and Chairman of the Joint Expert Group for Vietnam. Participants attended including delegate of Cambodia and Vietnam, and officials of MOWRAM, MONRE, CNMC,VNMC, and staff of MRCS and the Officials from Provincial Department of Water Resources and Meteorology of Cambodia of Ratanakiri, Svay Rieng, Takeo and Prey Veng .









សកម្មភាពកិច្ចប្រជុំនៃប្រតិភូកម្ពុជានិងវៀតណាម
Meeting Activities between Cambodia and Viet Nam Delegates

# II. សកម្មភាពអនុវត្តគម្រោងនិងកម្មវិធីនានា

## Implementation of projects and programmes

| | |
|---|---|
| ❍ ដំណើរការវិមជ្ឈការ-មុខងារស្នូល | Decentralization and Core Functions |
| ❍ គម្រោងគ្រប់គ្រងធនធានទឹកចម្រុះឆ្លងដែន | M-IWRMP Transboundary Projects |
| ❍ គម្រោងគ្រប់គ្រងធនធានទឹកចម្រុះថ្នាក់ជាតិ | National M-IWRM Projects |
| ❍ កម្មវិធីផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ | Basin Development Plan Programme |
| ❍ ផែនការចង្អុលថ្នាក់ជាតិដើម្បីអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេ | National Indicative Plan for MRC Basin Development Strategy |
| ❍ ការអនុវត្តគម្រោងសាកល្បងនៃផែនការចង្អុលថ្នាក់ជាតិ | Implementation of Pilot Project for National Indicative Plan for MRC Basin Development Strategy |
| ❍ សកម្មភាពបណ្តុះបណ្តាលដោយ BDP | Training Activities under BDP |
| ❍ កម្មវិធីបន្សាំការប្រែប្រួលអាកាសធាតុ | Climate Change and Adaptation Initiative Programme |
| ❍ ដំណើរទស្សនកិច្ចសិក្សា | Study Tours |
| ❍ សន្និសីទអន្តរជាតិ Rhine-Mekong និង ទស្សនៈកិច្ចសិក្សានៅកាន់ទន្លេ Elbe នៅប្រទេសអាឡឺម៉ង់ ០៧-១៨ ខែ ឧសភា ឆ្នាំ ២០១៤ | International Symposium on Rhine-Mekong and Study Tour in Elbe Basin from 7-18 May 2014. |
| ❍ ការបំពេញវគ្គសិក្សាក្រៅប្រទេស | Study Abroad |

## ដំណើរការវិមជ្ឈការ-មុខងារស្នូល (Decentralization and Core Functions)



ឯកឧត្តម **ស៊ិន នីនី** អនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាដឹកនាំកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ

H.E Mr. Sin Niny Permanent Vice-Chairman of CNMC Chairs the National Workshop

វិមជ្ឈការមុខងារស្នូល គឺជាដំណើរការមួយដែលក្នុងនោះស្ថាប័នជាតិ នៃប្រទេសជាសមាជិកទទួលខុសត្រូវលើផ្នែកហិរញ្ញវត្ថុនិងការអនុវត្ត។ គោលបំណងសំខាន់នៃការអនុវត្តវិមជ្ឈការមុខងារស្នូលគឺ (១) ពង្រឹងភាពជាម្ចាស់ការរបស់ប្រទេសជាសមាជិក(២)ពង្រឹងសកម្មភាពរបស់ប្រទេសជាសមាជិក និង (៣) ធានាប្រសិទ្ធភាព និងនិរន្តរភាពផ្នែកហិរញ្ញវត្ថុសម្រាប់ប្រតិបត្តិការ MRC។ ការប្តេជ្ញាចិត្តរបស់ប្រមុខរដ្ឋាភិបាល នៃប្រទេសជាសមាជិកបានឯកភាពនៅក្នុងកិច្ចប្រជុំកំពូល MRC លើកទី១ នាដើមខែមេសា ឆ្នាំ២០១០ នៅហួហ៊ីន ប្រទេសថៃឲ្យមានស្វ័យភាពទាំងស្រុងខាងហិរញ្ញវត្ថុនៅឆ្នាំ២០៣០។

នៅក្នុងកិច្ចប្រជុំកំពូលនេះ ត្រូវបានបញ្ចូលនៅក្នុងផែនការយុទ្ធសាស្ត្រ MRC ឆ្នាំ ២០១១-២០១៥ ហើយដើម្បីអនុវត្តនូវការប្តេជ្ញាចិត្តនេះ MRC បាននឹងកំពុងស្ថិតក្នុងដំណើរការរៀបចំផែនទីបង្ហាញផ្លូវមួយសម្រាប់ការធ្វើវិមជ្ឈការ និងមុខងារស្នូលនៃការគ្រប់គ្រងអាងទន្លេក្នុងនោះមាន (១) ការទទួលការផ្លោះប្តូរ និងការតាមដានទិន្នន័យ(២)ការវិភាគ ការធ្វើម៉ូដែល និងការវាយតម្លៃ(៣) ការគាំទ្រដល់ការកសាងផែនការ (៤)ការព្យាករណ៍ ការផ្តល់ព័ត៌មានជាមុន និងការឆ្លើយតប និងករណីបន្ទាន់ (៥) ការអនុវត្តតាមនីតិវិធីរបស់គណៈកម្មការទន្លេមេគង្គ (៦) ការជំរុញឲ្យមានការសន្ទនា និងការសម្របសម្រួល និង (៧)ការធ្វើសេចក្តីរាយការណ៍ និងការផ្សព្វផ្សាយព័ត៌មាន។

Decentralization and Core Function is a process in which the institutions of the member countries responsible for finance and implementation. The main purpose of the implementation of decentralization and core function are (1) to strengthen the ownership of member countries (2) to strengthen the activities of the members, and (3) to ensure efficient and financially sustainable operation of MRC. The commitment of the heads of Government of the member countries have agreed in the 1st MRC Summit in early April 2010, Hua Hin, Thailand for self finance completely in 2030.

In the Summit there was included in the MRC Strategic Plan 2011-2015 and to implement the commitment, MRC has been in the process for preparing a roadmap for the decentralization and core functions for basin management in which there are (1) Data acquainting exchange and monitoring (2) analysis, modeling and assessment (3) planning support (4) Forecasts warning and emergency cases (5) implementating of MRC procedures (6) response promoting and coordination, and (7 ) reporting and dissemination.



សកម្មភាពកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិលើឯកសារវិមជ្ឈការ និងមុខងារស្នូល National Consultation Activities on Decentralization and Core Functions

# គម្រោងគ្រប់គ្រងធនធានទឹកចម្រុះឆ្លងដែន
# M-IWRMP Transboundary Projects

ក្រោមជំនួយថវិការបស់ធនាគារពិភពលោក តាមរយៈគណៈកម្មការទន្លេមេគង្គ គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាបានដឹកនាំ និងសម្របសម្រួលការរៀបចំគម្រោងឆ្លងដែនចំនួន៣ គឺ ១) រវាងកម្ពុជា-វៀតណាម ស្តីពីការគ្រប់គ្រងធនធានទឹកចម្រុះឆ្លងដែនសម្រាប់អនុតំបន់ដីសណ្តមេគង្គនិងទន្លេសេសាន-ស្រែពក (២) រវាងកម្ពុជាឡាវស្តីពីការគ្រប់គ្រងធនធានជលផលសម្រាប់អនុតំបន់មេគង្គ និងទន្លេសេកុង (៣) រវាងកម្ពុជា-ថៃ ស្តីពីកិច្ចសហប្រតិបត្តិការលើការអនុវត្ត IWRM សម្រាប់ការគ្រប់គ្រងបឹងទន្លេសាបនៅកម្ពុជានិងបឹងសុងក្លានៅថៃ។

Under the financial support of the World Bank through Mekong River Commission, the Cambodia National Mekong Committee leads and coordinates for preparation and implementation of three transboundary cooperation projects namely (1) between the Cambodia - Vietnam on Integrated Water Resources Management for Mekong Delta and Se San- Sre Pok Sub-Areas (2) between the Cambodia - Lao PDR on Joint Fisheries Management for the Mekong and Se Kong Rive Sub-Areas, and (3) between Cambodia - Thailand on Communication Outreach Project on the implementation of IWRM for Lake Management of Tonle Sap in Cambodia and Songkhla Lake in Thailand.

### ១. គម្រោងឆ្លងដែនរវាងកម្ពុជា-វៀតណាមស្តីពី ការគ្រប់គ្រងធនធានទឹកចម្រុះឆ្លងដែនសម្រាប់អនុតំបន់ដីសណ្តមេគង្គនិងទន្លេសេសាន-ស្រែពក

គោលបំណងទូទៅនៃគម្រោង គឺដើម្បីធ្វើឲ្យប្រសើរឡើងនូវការពិភាក្សារវាងប្រទេសទាំងពីរ ហើយគម្រោងនេះ ត្រូវបានបង្កើតឡើង ដោយផ្អែកតាមគោលការណ៍គ្រប់គ្រងធនធានទឹកចម្រុះ (IWRM) សម្រាប់កិច្ចសហប្រតិបត្តិការនិងការសន្ទនាឆ្លងដែនរវាងប្រទេសកម្ពុជា និងវៀតណាមនៅក្នុងអនុតំបន់ដីសណ្តមេគង្គ និងទន្លេសេសាន-ស្រែពកនៅកម្រិតថ្នាក់ខេត្តនិងអាងទន្លេ។

គោលបំណងជាក់លាក់គឺដើម្បី៖ (១) កំណត់នូវបញ្ហាពាក់ព័ន្ធនៃការគ្រប់គ្រងទឹកឆ្លងដែនសំខាន់ៗ (២) បង្កើតយន្តការសហការដើម្បីផ្លាស់ប្តូរ និងចែករំលែកទិន្នន័យ និងព័ត៌មានឆ្លងដែន (៣) បង្កើតកិច្ចសន្ទនាឆ្លងដែនផ្អែកតាមគោលការណ៍ IWRM ដោយមានប្រសិទ្ធភាពរវាងប្រទេសទាំងពីរ ដើម្បីបង្កើតផែនការពិនិត្យតាមដានអាងទន្លេនាពេលខាងមុខ ក្នុងអនុតំបន់ដីសណ្តមេគង្គនិងទន្លេសេសាន-ស្រែពក។

The overall aim of the projects is to enhance dialogue between two countries and it is formulated as: The IWRM-based transboundary cooperation and dialogue between Cambodia and Viet Nam in the Mekong Delta and Sesan-Srepok sub-basins, focussing at provincial and basin level are improved.

The project specific objectives are (1) Transboundary Significant Water Management Issues is identified. (2) Mechanism for transboundary data and information processing and sharing is established. (3) An effective IWRM-based transboundary dialogue between the two countiers is established for river monitoring plan in the Mekong Delta and in the Sesan and Srepok Sub Basins.






ឯកឧត្តម **តែ ណាវុធ** អគ្គលេខាធិការ គ.ជ.ទ.ម.ក. និងលោកបណ្ឌិត LE DUC TRUNG អគ្គលេខាធិការ គ.ជ.ទ.ម.វ. បានពិនិត្យលើលក្ខខណ្ឌការងារគម្រោងរវាងកម្ពុជា-វៀតណាម នាថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០១៤ នៅខេត្តសៀមរាប កម្ពុជា

H.E Mr. TE NAVUTH, Secretary General, CNMC and Dr. LE DUC TRUNG, Director General of VNMC reviewed the TOR for joint implementation of the Project between Cambodia and Viet Nam, 13 June 2014, Siem Reap, Cambodia






## ២. គម្រោងឆ្លងដែនរវាង កម្ពុជា-ឡាវ ស្ដីពីការគ្រប់គ្រងធនធានជលផលសម្រាប់អនុតំបន់មេគង្គនិងទន្លេសេកុង

គោលបំណងនៃគម្រោង គឺការលើកកម្ពស់ការគ្រប់គ្រងជលផលនៅតាមបណ្ដាខេត្តតាមព្រំដែន នៃខេត្តស្ទឹងត្រែងនិងក្រចេះនៅកម្ពុជា និងខេត្តចំប៉ាសាក់និងអាតាពឺនៅឡាវ។ លទ្ធផលសំខាន់ដែលសម្រេចបាននូវគោលបំណងរួមខាងលើ៖(១) កម្មវិធីត្រួតពិនិត្យតាមដានជលផលក្នុងតួនាទីរបស់ទន្លេមេគង្គនិងសេកុង។ (២) ការពិភាក្សាអំពីជលផលដោយប្រសិទ្ធភាពរវាងកម្ពុជានិងឡាវ។ (៣) កិច្ចសហប្រតិបត្តិការឆ្លងដែននៅក្នុងតួនាទីគ្រប់គ្រងជលផល។

## Transboundary project between Cambodia-Lao PDR on Fisheries Management for Mekong and Sekong Sub-basin

The Overall objective of the project is that “Fisheries management improved in the bordering provinces of Stung Treng and Kratie in Cambodia and Champassak and Attapeu in Lao PDR”.

The following three outcomes contributing to the achievement of the overall project objective: (1) Joint Fisheries Monitoring programme in Mekong and Sekong functioning. (2) Effective fisheries dialogue between Cambodia and Lao PDR. (3) Transboundary cooperation in fisheries management functioning.



សកម្មភាពសិក្ខាសាលា កម្ពុជា -ឡាវ ថ្ងៃទី ១៨-១៩ ខែមិថុនា ឆ្នាំ ២០១៤ នៅក្រុងប៉ាក់សេ ខេត្តចំប៉ាសាក់ ប្រទេសឡាវ

Workshop Activities between Cambodia-Lao PDR 18-19 June 2014, Pakse, Champa Sak Province, Lao PDR

## ៣. គម្រោងរវាងកម្ពុជា- ថៃស្ដីពីកិច្ចសហប្រតិបត្តិការលើការអនុវត្ត IWRM សម្រាប់ការគ្រប់គ្រងបឹងទន្លេសាបនៅកម្ពុជា និងបឹងសុងក្លានៅថៃ

គោលបំណងទូទៅនៃគម្រោង គឺអភិបាលកិច្ចល្អសម្រាប់ធនធានក្នុងការគាំទ្រដល់បឹងទន្លេសាប និងបឹងសុងក្លាប្រកបដោយសុខាមាលភាពនិងល្អប្រសើរសម្រាប់ជាប្រយោជន៍នៃជីវភាពរស់នៅដោយនិរន្តរភាព និងការថែរក្សាសម្រាប់ជាគំរូដល់បឹងផ្សេងទៀត។ បឹងទន្លេសាប គឺជាបឹងដែលធំជាងគេនៅអាស៊ីអាគ្នេយ៍រីឯបឹងសុងក្លា គឺជាបឹងធម្មជាតិធំជាងគេនៅប្រទេសថៃ។ បឹងទាំងពីរគឺមានសារៈប្រយោជន៍ខ្ពស់ដល់វប្បធម៌បរិស្ថាន សេដ្ឋកិច្ច និងសង្គម។ លទ្ធផលខាងក្រោមនេះគឺជាសមិទ្ធផលសម្រាប់ការសម្រេចបាននូវគោលបំណងរួម៖

១.ការគ្រប់គ្រងគម្រោងដើម្បីលើកកម្ពស់ដល់ផ្នែករដ្ឋបាលនិងការគ្រប់គ្រងរួមមានរដ្ឋបាលផ្ទៃក្នុង ក៏ដូចជាការចូលរួមនិងទំនាក់ទំនងរបស់ភ្នាក់ងារសាធារណៈ ដៃគូរការងារ អ្នកពាក់ពន្ធ័ និងម្ចាស់ជំនួយអន្តរជាតិ។

២.អភិបាលកិច្ចផ្អែកលើIWRMដើម្បីលើកកម្ពស់អភិបាលកិច្ច ដោយមានការសម្របសម្រួលរវាងបណ្ដាភ្នាក់ងារ អ្នកប្រើប្រាស់ទឹក និងអ្នកពាក់ព័ន្ធផ្សេងទៀត និងការចែករំលែកចំណេះដឹងក្នុងចំណោមកម្រិតគ្រប់គ្រងនិងរវាងវិស័យនានា។

៣. ជីវភាពរស់នៅផ្អែកលើធនធាននាពេលអនាគត ដើម្បីលើកកម្ពស់ការយល់ដឹង ទំនាក់ទំនងរវាងបរិស្ថាន សង្គម និងសេដ្ឋកិច្ច និងជម្រើសគោលនយោបាយ ក្នុងការគាំទ្រជីវភាពរស់នៅផ្អែកលើធនធានប្រកបដោយនិរន្តរភាព។

៤. សុខាមាលភាពបឹង ដើម្បីកសាងសមត្ថភាព និងចំណេះដឹងរវាងភ្នាក់ងារ និងសហគមន៍មូលដ្ឋាន អំពីថាតើឬ ធ្វើយ៉ាងណាដើម្បីទទួលបានផលប្រយោជន៍ និងថែរក្សាបរិស្ថានដោយនិរន្តរភាព៕



## Communication Outreach Project between Cambodia and Thailand on IWRM implementation in Tonle Sap and Songkhla lake basin

The overall objective of the project is “Good resource governance in support of prosperous and healthy Songkhla and Tonle Sap lake basin, for the benefit of sustainable livelihoods, and serving as an example for inspiration elsewhere”. Songkhla Lake is the largest natural lake in Thailand, and Tonle Sap Lake is the largest lake in Southeast Asia. Both lakes have a high social, economic, environmental and cultural significance.

The following outcomes will contribute to the achievement of the overall project objective:

1. Programme management: Improved project management and administration, including internal organization administration, as well as communication and involvement of public agencies, working partners, other relevant actors and international donors.

2. IWRM-based governance: IWRM-based governance strengthened and consolidated, in collaboration among agencies, water users and other stakeholders, and with appropriate knowledge-sharing among management levels and among sectors.

3. The future of resource-based livelihoods: Improved understanding of social, economic and environmental cause-effect relationships and policy options in support of sustainable, resource-based livelihoods.

4. Healthy lakes: Understanding built and awareness raised among agencies and residents about why and how to achieve and preserve a healthy state of the environment.





ឯកឧត្តម **តែ ណាវុធ** អគ្គលេខាធិការ គជទមក អ្នកស្រី Pakawan Chufamanee នាយកផ្នែកគ្រប់គ្រងមេគង្គ គ.ជ.ទ.ម.ថ. និងលោក Hans Guttman នាយកប្រតិបត្តិ ក្នុងឱកាសសិក្ខាសាលាប្រកាសចាប់ផ្ដើមអនុវត្តគម្រោងរវាងកម្ពុជា-ថៃ នាថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៣ នៅខេត្តសៀមរាប កម្ពុជា

H.E Mr. TE NAVUTH, Secretary General, CNMC, Mrs. Pakawan Chufamanee, Director, Bureau of Mekong Management, TNMC and Mr. Hans Gutman, MRC CEO in the Launching Workshop for joint implementation of the Project between Cambodia and Thailand, 13 September 2013, Siem Reap, Cambodia

# គម្រោងគ្រប់គ្រងធនធានទឹកចម្រុះថ្នាក់ជាតិ

## National M-IWRM Projects

គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាបានសហការជាមួយក្រសួងពាក់ព័ន្ធផ្តួចផ្តើមគម្រោងគ្រប់គ្រងធនធានទឹកចម្រុះថ្នាក់ជាតិក្នុងជំហានទី៣ ក្រោមក្របខ័ណ្ឌ គណៈកម្មការទន្លេមេគង្គដើម្បីស្នើសុំឥណទានកម្ចីពីធនាគារពិភពលោករួមមានគម្រោងគ្រប់គ្រងជលផលនិងវារីវប្បកម្ម និងគម្រោងគាំទ្រការគ្រប់គ្រងអាងទន្លេនៅក្នុងអនុតំបន់សេសាន-ស្រែពកនិងអាងព្រែកទាំង៤ នៅភូមិភាគឦសាន កម្ពុជា។ រដ្ឋបាលជលផលទទួលបន្ទុកគម្រោងគ្រប់គ្រងជលផល និងអភិវឌ្ឍវារីវប្បកម្មក្នុងខេត្តក្រចេះ និងស្ទឹងត្រែងដែលនឹងមានបញ្ចូលការសាងសង់កន្លែងបង្កាត់ពូជត្រីថ្មីមួយកន្លែងនៅខេត្តស្ទឹងត្រែង ដែលមានទឹកប្រាក់១០,៨ លានដុល្លារអាមេរិក។ គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាសហការជាមួយក្រសួងធនធានទឹក និងឧតុនិយមទទួលបន្ទុកគម្រោងគាំទ្រការគ្រប់គ្រងអាងទន្លេ ដែលមានថវិកា៥,១ លានដុល្លារអាមេរិក៕

Cambodia National Mekong Committee has cooperated with the relevant line ministries initiated the National M-IWRMP Phase 3 under the MRC framework to request loan from the World Bank, including the Support Fisheries and Aquatic Resources Management and support basin management in sub-basin of Sekong, Sesan and Srepok rivers in northeast of Cambodia. Fisheries Administration is responsible for the project Support Fisheries and Aquatic Resources Management in Kratie and Stung Treng, which will include construction of a new fish hatchery in the Stung Treng Province with the amount of US$ 10.8 million. Cambodia National Mekong Committee in cooperation with the Ministry of Water Resources and Meteorology in charge of project support the river basin management with a budget of US$ 5.1 million.










សកម្មភាពកិច្ចប្រជុំពិគ្រោះយោបល់និងសកម្មភាពប្រតិភូធនាគារពិភពលោក និង មន្ត្រីកម្ពុជាទស្សនាកិច្ចក្នុងតំបន់គម្រោង
Consultation Meetings and WB Delegate and Cambodia Officials Visited the Project Areas

# កម្មវិធីផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ

## Basin Development Plan Programme (BDP)

គោលបំណងនៃផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងមេគង្គ ១៩៩៥ ដែលគាំទ្រដល់ដំណើរការកសាងផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ។ កម្មវិធី BDP បានបង្កើតឡើង ដើម្បីសម្របសម្រួលដំណើរការកសាងផែនការរបស់ប្រទេសជាសមាជិកផ្សារភ្ជាប់នឹងផែនការអាងទន្លេមេគង្គថ្នាក់តំបន់ទាំងមូលផ្អែកតាមគោលការណ៍គ្រប់គ្រងធនធានទឹកចម្រុះ។

គោលបំណងទូទៅរបស់កម្មវិធី BDP សម្រាប់ ឆ្នាំ២០១១-២០១៥ ស្របគ្នានឹងគោលដៅរបស់ផែនការយុទ្ធសាស្ត្រ MRC ២០១១-២០១៥ ដែលប្រទេសជាសមាជិកទាំងអស់អនុវត្តអភិក្រមគ្រប់គ្រងធនធានទឹកចម្រុះ (IWRM) ទៅក្នុងក្របខ័ណ្ឌផែនការនិងអភិវឌ្ឍន៍វិស័យទឹក និងវិស័យពាក់ព័ន្ធថ្នាក់ជាតិដើម្បីជំរុញការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងសមធម៌។ កម្មវិធី BDP គាំទ្រដល់បណ្ដាប្រទេសជាសមាជិកក្នុងការបញ្ចូល និងការអនុវត្តគោលការណ៍ការណែនាំ និងដំណើរការក្នុងយុទ្ធសាស្ត្រអភិវឌ្ឍអាងទន្លេផ្អែកតាមគោល - ការណ៍ IWRM នៅក្នុងការកសាងផែនការ និងប្រព័ន្ធច្បាប់របស់ជាតិ។

កម្មវិធី BDP ២០១១-២០១៥ បានដំណើរការដោយសម្រេចបានលទ្ធផលធំៗ រួមមាន៖

១. យុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេផ្អែកតាមគោលការណ៍ IWRM

២. ផែនការចង្អុលថ្នាក់ជាតិ ផែនការសកម្មភាពតំបន់ និងផែនការសកម្មភាពអាងទន្លេ

៣. ប្រព័ន្ធព័ត៌មានសេដ្ឋកិច្ច និងសង្គម

៤. ការសិក្សា និងវិភាគអនុតំបន់ក្នុងប្រទេស

៥. ឯកសារវិភាគសេណារីយ៉ូ

៦. ចងក្រងប្រវត្តិ BDP៕



The purpose of the BDP is clearly stipulated in the 1995 Mekong Agreement, which supports the process of Basin Development Plan and MRC BDP was established to coordinate the planning process of the member countries linking to Mekong Basin Plan as the whole based on the IWRM principles.

The overall objective of the BDP 2011-2015 is consistent with the goals of the MRC Strategic Plan 2011-2015, which all member countries implement IWRM approach (IWRM) in the national planning and development framework of water and related sectors to promote sustainable and equitable development.

BDP supports member countries in the process and implementation of policy guidance and strategic development of the basin based on IWRM principles in the national planning and legal system.

Implementation of BDP 2011-2015 has achieved major results satisfactorily, including:

1. IWRM-based Basin Development Strategy
2. National Indicative Plan, Regional Action Plan and Basin Action Plan
3. Database for socio-economic information system
4. Sub-area Study and analysis Profiles
5. BDP Scenario Assessment
6. Compiled BDP Story.

# ផែនការចង្អុលថ្នាក់ជាតិដើម្បីអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍ អាងទន្លេរបស់គណៈកម្មការទន្លេមេគង្គ

# National Indicative Plan for MRC Basin Development Strategy






ឯកឧត្តម **ស៊ិន នីនី** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ទ.ម.ក. ដឹកនាំសិក្ខាសាលា

H.E SIN NINY Permanent Vice-Chairmam of CNMC chairs the National Workshop

គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា បានដឹកនាំដំណើរការរៀបចំនូវឯកសារផែនការចង្អុលថ្នាក់ជាតិ ដើម្បីអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេរបស់គណៈកម្មការទន្លេមេគង្គ។

ឯកសារផែនការបានបង្កើតឡើង និងបានពិនិត្យពិគ្រោះយោបល់ថ្នាក់ជាតិតាមរយៈសិក្ខាសាលាថ្នាក់ជាតិ ដែលសម្របសម្រួល និងដឹកនាំដោយគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា។ ឯកសារផែនការបានអនុម័តដោយ ឯកឧត្តម **លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម និងជាប្រធាន គ.ជ.ទ.ម.ក. នៅខែឧសភា ឆ្នាំ២០១៣។

Cambodia National Mekong Committee, led the process of preparing of the National Indicative Plan (NIP) to implement the MRC Basin Development Strategy. Plan established and examined through national consultation workshops coordinated and led by the Cambodia National Mekong Committee. NIP was approved by H.E Mr. LIM KEAM HOR, Minister of Ministry of Water Resources and Meteorology and Chairman of CNMC, May 2013.





សកម្មភាពកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិស្តីពី NIP

National Consultation Activities on NIP





# ការអនុវត្តគម្រោងសាកល្បង នៃផែនការចង្អុលថ្នាក់ជាតិ

## Implementation of Pilot Project for National Indicative Plan for MRC Basin Development Strategy

គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា បានពិភាក្សានិងពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋានស្តីពីការចាប់ផ្តើមគម្រោងសាកល្បងនៃការអនុវត្តផែនការចង្អុលថ្នាក់ជាតិស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងគ្រប់គ្រងធនធានទឹកក្នុងអនុតំបន់ទន្លេសាប ក្រោមការគាំទ្រថវិការបស់គណៈកម្មការទន្លេមេគង្គ នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៣ នៅឃុំជ្រៃលាស់ ស្រុកពញាឮ ខេត្តកណ្តាល។ គម្រោងនឹងអនុវត្តក្នុងទីតាំងគំរូមួយសម្រាប់ការសិក្សាលំអិតលើការកសាងផែនការអភិវឌ្ឍន៍អាងវាលទំនាបឃុំជ្រៃលាស់ ដែលជាផ្នែកមួយនៃអាងទឹកស្ទឹងក្រាំងពន្លៃនៃអនុតំបន់ទន្លេសាប៕

Cambodia National Mekong Committee leads discussion and consultation with local communities on the kick-off of National Indicative Plan Pilot Project on Basin Development Plan for Tonle Sap Sub-Area under MRC BDP Financial support, 30 December 2013, Chrey Loas Commune, Ponhea Leu District, Kandal Province. The project will be implemented in a pilot location for the detail study on the Basin Development Plan in Chrey Loas floodplain , part of the Krain Ponley River basin, Tonle Sap sub-area.













សកម្មភាពសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការអនុវត្តគម្រោងសាកល្បងអនុវត្ត NIP ឃុំជ្រៃលាស់ ខេត្តកណ្តាល
Consultation Workshop Activities on NIP Pilot Project Implementation, Chrey Loas Commune, Kandal Province

# សកម្មភាពបណ្តុះបណ្តាលដោយ BDP
# Training Activities under BDP





តាមរយៈBDP គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា បាន រៀបចំសិក្ខាសាលាបណ្តុះបណ្តាលជូនក្រសួង ស្ថាប័នជាសមាជិករួមមានផ្នែកគ្រប់គ្រងធនធានទឹកចម្រុះ ផ្នែកបញ្ជ្រាបយេនឌ័រក្នុងការអភិវឌ្ឍ និងគ្រប់គ្រងធនធានទឹក ផ្នែកចរចារជាដើម ដើម្បីពង្រឹងសមត្ថភាពចំណេះដឹងបន្ថែមជូនមន្ត្រីរាជការ។ ការបណ្តុះបណ្តាលបានរៀបចំដោយមានក្រុមការងារបណ្តុះបណ្តាលដែលមានតំណាងមកពីក្រសួងជំនាញ ហើយបានទទួលការបណ្តុះបណ្តាលជាគ្រូបង្វឹកដោយគណៈកម្មការទន្លេមេគង្គបន្តមកបណ្តុះបណ្តាលថ្នាក់ជាតិ។ ឯកសារបណ្តុះបណ្តាលមានជាភាសាខ្មែរ ក្នុងនោះឯកសារបណ្តុះ-បណ្តាលការគ្រប់គ្រងធនធានទឹកចម្រុះនិងគ្រប់គ្រងអាងទន្លេ។ មន្ត្រីថ្នាក់ខេត្តមកពីមន្ទីរពាក់ព័ន្ធនៃខេត្តទូទាំងប្រទេស និងសហគមន៍ប្រជាពលរដ្ឋក្នុងខេត្តពាក់ព័ន្ធក៏ទទួលបានការបណ្តុះបណ្តាលកម្រិតជំនាញផងដែរ។

With the cooperation and financial support through MRC Secretariat, Cambodia National Mekong Committee have organized series of training workshop activities for member ministries and line agencies on IWRM, Gender mainstreaming in water resource development and management, negotiation process and methods to strengthen and suplement their knowledge and skills. The Training Team for IWRM was established by CNMC, who are from relavent ministries and were trained by MRC for TOT, conducted the training activities. The Training documents are available in Khmer such for IWRM and River Basin Management. Provincial officials and also other communities were trained on relevant skills.





សកម្មភាពសិក្ខាសាលាបណ្តុះបណ្តាល Training Workshop Acivities





# កម្មវិធីបន្សាំការប្រែប្រួលអាកាសធាតុ
# Climate Change and Adaptation Initiative Programme

កម្មវិធីបានដំណើរការ និងសម្រេចបានលទ្ធផលរួមមាន៖

- បានរៀបចំបង្កើតទិន្នន័យ និង ប្រព័ន្ធវាយតម្លៃការប្រែប្រួលអាកាសធាតុ និង ការបន្សាំ
- បានវាយតម្លៃតម្រូវការសមត្ថភាពថ្នាក់ជាតិសម្រាប់កម្មវិធីប្រែប្រួលអាកាសធាតុ និងការបន្សាំ
- បានផ្សព្វផ្សាយលទ្ធផល មេរៀន និងបទពិសោធន៍ព្រមទាំងចែករំលែកលទ្ធផលទៅដល់សហគមន៍មូលដ្ឋាន អ្នកពាក់ព័ន្ធថ្នាក់ខេត្ត ថ្នាក់ជាតិនិងលើកកំពស់ការយល់ដឹងអំពីការបន្សាំទៅនឹងកាប្រែប្រួលអាកាសធាតុ
- បានរៀបចំសំយោគបណ្ណាល័យសាស្ត្រ ពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុនិងការបន្សាំ ក្រោមបរិបទបរិស្ថានទឹកក្នុងអាងទន្លេមេគង្គភាគខាងក្រោមរបស់គណៈកម្មការទន្លេមេគង្គ៕
- បានបញ្ជ្រាបយេនឌ័រទៅក្នុងការងារ និងដំណើរការបន្សាំនឹងការប្រែប្រួលអាកាសធាតុ

The Programme proceeds and achieved following outputs include:

- Established database system and assessment of climate change and adaptation
- Assessed national capacity for climate change and adaptation
- Disseminated the results, lessons learnt and experiences as well as sharing the result to the local community, provincial and national stakeholders and raised awareness about climate change adaptation
- Prepared litteraure review related to climate change and adaptation under water environmental context in the Lower Mekong Basin.
- Mainstreamed Gender perspectives into climate change and adaptation process and activities.








សកម្មភាពកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីកម្មវិធីបន្សាំការប្រែប្រួលអាកាសធាតុ
National Consultation Activities of Climate Change and Adaptation Initiative Programme

# ដំណើរទស្សនកិច្ចសិក្សា Study Tours

ប្រតិភូកម្ពុជា ឡាវ ថៃ និង វៀតណាម ព្រមទាំងលេខាធិការដ្ឋានចូលរួមដំណើរទស្សនៈកិច្ចសិក្សាដែលរៀបចំដោយMRC ទៅកាន់ប្រទេសអូទ្រីស ស្លូវ៉ាគី ហុងហ្គារី និង អាល្លឺម៉ង់ ដែលជាសមាជិកគណៈកម្មការសម្រាប់ការពារទន្លេ DANUBE ចាប់ពីថ្ងៃទី២៤ ខែមីនា រហូតដល់ថ្ងៃទី០៤ ខែមេសា ឆ្នាំ ២០១២ ក្នុងគោលបំណងស្វែងយល់ពីការកសាង ការអនុវត្តផែនការទន្លេ DANUBE ដើម្បីទទួលបានជាមេរៀននិងបទ - ពិសោធន៍យកមកអនុវត្តនៅក្នុងក្របខ័ណ្ឌគណៈកម្មការទន្លេមេគង្គលើការកសាងនិងការអនុវត្តផែនការគ្រប់គ្រងធនធានទឹក នៅក្នុងអាងទន្លេមេគង្គ។ ប្រតិភូកម្ពុជាមកពីគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាក្រសួងធនធានទឹកនិងឧតុនិយម និង អាជ្ញាធរទន្លេសាប ដឹកនាំដោយ ឯកឧត្តម **តែ ណាវុធ** អគ្គលេខាធិការ គ.ជ.ទ.ម.ក.៕

Cambodia, Laos, Thailand and Vietnam Delegates attended the study visit organized by MRC to Austria, Slovakia, Hungary and Germany, members of the Commission for the protection of the river DANUBE (International Commission for the Protection of Danube River -ICPDR) on 24 March to 04 April 2012 to learn the experience and knowledge on Danube River Basin Development Framework and its implementation with the commission of Danube River and gain back the good experience and knowledge applying at the MRC Mekong Water Resources and Basin Development Framework.

Cambodia Delegate from CNMC, MOWRAM and TSA that led by H.E Mr. TE NAVUTH, Secretary General, CNMC.





ឯកឧត្តម **តែ ណាវុធ** ប្រធានប្រតិភូកម្ពុជា ថ្លែងចំណាប់អារម្មណ៍ក្នុងកិច្ចប្រជុំពិភាក្សា

H.E Mr. TE NAVUTH Cambodia Delegate Head expresses his statement in the Discussion Meeting





សកម្មភាពរបស់គណៈប្រតិភូ Delegate Activities

ប្រតិភូកម្ពុជា ឡាវ ថៃ និងវៀតណាម ព្រមទាំងលេខាធិការដ្ឋានបានចូលរួមដំណើរទស្សនៈកិច្ចសិក្សា ដែលបានរៀបចំដោយគណៈកម្មការទន្លេមេគង្គ ដើម្បីផ្លាស់ប្តូរបទពិសោធន៍ការកសាងផែនការអាងទន្លេមេគង្គ និងអាងទន្លេ MURRAY DARLING នៃប្រទេសអូស្ត្រាលីពី ថ្ងៃទី២៣ ខែកុម្ភៈ ដល់ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៣។ ប្រតិភូកម្ពុជាមានមន្ត្រីមកពីគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និង ក្រសួងធនធានទឹក និងឧតុនិយម៕

Cambodia, Laos, Thailand and Vietnam Delegates attended the study visit to Australia, which conducted by the MRC to the Murray Darling Authority for sharing the experience and knowledge on Basin Development Plan on Mekong Basin and Murray Darling Basin, 24 Feb -3 March 2013. Cambodia Delegate are officials from CNMC and MOWRAM.









សកម្មភាពរបស់គណៈប្រតិភូ Delegates Activities

# សន្និសីទអន្តរជាតិ Rhine-Mekong និង ទស្សនៈកិច្ចសិក្សាទៅកាន់ទន្លេ Elbe

## នៅប្រទេសអាឡឺម៉ង់ នាថ្ងៃទី០៧-១៨ ខែឧសភា ឆ្នាំ២០១៤

## International Symposium on Rhine-Mekong and Study Tour in Elbe Basin from 7-18 May 2014.



ប្រតិភូអន្តរក្រសួងរបស់កម្ពុជា រួមមានតំណាងជាន់ខ្ពស់មកពីក្រសួងធនធានទឹក និងឧតុនិយម ក្រសួងបរិស្ថាន និង គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាចូលរួមសន្និសីទអន្តរជាតិ Rhine-Mekong និងទស្សនៈកិច្ចសិក្សាទៅកាន់ទន្លេ Elbe នៅប្រទេសអាឡឺម៉ង់ នាថ្ងៃទី០៧-១៨ ខែឧសភា ឆ្នាំ២០១៤ ដើម្បីដោះដូរបទពិសោធន៍ពាក់ព័ន្ធការគ្រប់គ្រងទឹកជំនន់ និងការបន្សាំការប្រែប្រួលអាកាសធាតុ៕

Senior representatives from MOWRAM, MOE and CNMC attending International Symposium on Rhine-Mekong and Study Tour in Elbe Basin in Germany and Czech Republic from 7-18 May 2014. The aim of Symposium and Study Tour is to explore more cooperation and sharing experiences on flood management in the context of climate change.

ឯកឧត្តម **តែ ណាវុធ** ក្នុងនាមប្រធានប្រតិភូគណៈកម្មការទន្លេមេគង្គ ថ្លែងអំណរគុណដល់អភិបាលក្រុង Grimma ប្រទេសអាល្លឺម៉ង់ និងសហការី ដែលបានធ្វើបទបង្ហាញជម្រាបជូនប្រតិភូអំពីស្ថានភាពទឹកជំនន់ ឆ្នាំ២០១១ និងជូនដំណើរប្រតិភូចុះពិនិត្យទីតាំងគម្រោងសាងសង់ប្រព័ន្ធការពារទឹកជំនន់។

H.E Mr. Te Navuth on behalf of MRC Delegates thanked to Governor of Grimma Municipality and his colleagues who made presentation on flood situation in Grimma in 2011 and guided the visit of the delegates to the flood protection construction sites in Grimma Historical City of Germany.






ប្រតិភូចុះពិនិត្យប្រព័ន្ធការពារទឹកជំនន់ក្នុងក្រុង Dresden តាមដងទន្លេ Elbe។

MRC Delegates visited flood protection system in Dresden City along Elbe River.

## ការបំពេញវគ្គសិក្សាក្រៅប្រទេស Study Abroad

ឯកឧត្តម **សូ សុផ័ត្ត** ឯកឧត្តម **វ៉ាត់ បុត្តកុសល** និងឯកឧត្តម **ឡុង សារ៉ុវុធ** ចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពីការគ្រប់គ្រងធនធានទឹកចម្រុះ ដែលរៀបចំដោយទីភ្នាក់ងារអភិវឌ្ឍន៍នៃប្រទេសអូស្ត្រាលី (AusAID) និងវិទ្យាស្ថានបណ្ដុះបណ្ដាល និងអប់រំ (Chishom Institute) នៃរដ្ឋ Victory ប្រទេសអូស្ត្រាលី ពីថ្ងៃទី៨ ខែសីហា ដល់ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១១។ សិក្ខាកាមកម្ពុជា ចំនួន ២០ រូប មកពីថ្នាក់ជាតិ និងថ្នាក់ខេត្តនៃក្រសួង ស្ថាប័នពាក់ព័ន្ធ និងមានសាស្ត្រាចារ្យ និងអ្នកជំនាញការ និងអ្នកសម្របសម្រួល សរុប ១៨ រូប មកពីវិទ្យាស្ថាននានា និងពីសកលវិទ្យាល័យនៃក្រុង Melbourne រដ្ឋ Victory នៃទេសអូស្ត្រាលី។

Deputy Secretaries General of CNMC , HE So Sophort, HE Watt Botkosal and HE Long Saravuth attended the training courses on Integrated Water Resources Management organized by the Australian Agency for International Development (AusAID) and the Institute of Training and Education (Chishom Institute), the State University of Melbourne, from August 8 to 9 September 2011. There were 20 participants from the relevant Ministries and agencies and provincial agencies of Cambodia and instructed courses by 18 lecturers who are professors and experts and coordinators from the Institutes and the State University of Melbourne Victory of Australia.



## III. ឯកសារបោះពុម្ពរបស់គណៈកម្មការទន្លេមេគង្គ

## Publications of the Mekong River Commission




























































## យុទ្ធសាស្រ្តអភិវឌ្ឍន៍អាងទន្លេ (The IWRM-based Basin Development Strategy)

យុទ្ធសាស្រ្តនេះ ត្រូវបានអនុម័តដោយក្រុមប្រឹក្សាគណៈកម្មការទន្លេមេគង្គ នៅខែមករា ឆ្នាំ ២០១១។ យុទ្ធសាស្រ្តអភិវឌ្ឍន៍អាងទន្លេ ដែលត្រូវបានគាំទ្រ យ៉ាងទូលំទូលាយថាជាលទ្ធផលគោលដៅដ៏សំខាន់មួយសម្រាប់គណៈកម្មការ ទន្លេមេគង្គ បានទាក់ទាញ ជាបន្តបន្ទាប់លើការរកឃើញនិងការយល់ដឹងក្នុងអំឡុងពេលនៃការវាយតម្លៃសេណារីយ៉ូ យុទ្ធសាស្រ្តអភិវឌ្ឍន៍អាងទន្លេនេះបង្ហាញថា ការអភិវឌ្ឍអាងអាចអនុវត្តទៅ និងប្រព័ន្ធធម្មជាតិអាចការពារបាន ប្រសិនបើមានផែនការគ្រោងទុកបានល្អ។ យុទ្ធសាស្រ្តនេះ ពិពណ៌នាអំពីកម្លាំងរួមគ្នារវាងវិស័យទាក់ទងទឹកផ្សេងៗ (ទឹក ថាមពល ស្បៀង បរិស្ថាន ជាដើម) អាចប្រើប្រាស់ ដោះដូរ និងជៀសវាង ឬកាត់បន្ថយនូវផលប៉ះពាល់ជាសក្តានុពល ដោយផ្សារភ្ជាប់នឹងគោលការណ៍ IWRM និងការដោះស្រាយគម្លាតចំណេះដឹង។

This Basin Development Strategy was approved by the Council in January 2011. The Strategy, which was widely acclaimed as a major milestone for the MRC, drew progressively upon the findings and understandings reached during the scenario assessment as these emerged. The Basin Development Strategy demonstrates that basin development can take place and natural systems protected if planned well. The Strategy describes how synergies between the various water related sectors (water, energy, food, environment, etc.) can be exploited, trade-offs resolved, and potential downsides avoided or mitigated by adhering to IWRM principles and addressing knowledge gaps.




## សៀវភៅផែនទី Atlas ឆ្នាំ ២០១១ នៃអាងទន្លេមេគង្គក្រោម

### BDP-Planning Atlas 2011 of the Lower Mekong River Basin

សៀវភៅផែនទី Atlas មានគោលបំណង ដើម្បីជូនដំណឹងដ៏ទូលំទូលាយដល់ទស្សនិកជនដែលមិនមែនជាអ្នកជំនាញទាក់ទងនឹងទំហំនៃព័ត៌មានទាក់ទងនឹងដីនិងទឹកនៃអាងទន្លេមេគង្គ។ សៀវភៅផែនទីនេះ បានលើកទឹកចិត្តឱ្យអ្នកអានស្វែងយល់ផ្នែកនៃវិស័យផ្សេងគ្នា និងពិចារណាអំពីរបៀបដែលផ្នែកនិមួយៗមានឥទ្ធិពលលើការជ្រើសរើសដែលគណៈកម្មការទន្លេមេគង្គបានជួយ និងសម្របសម្រួលការគ្រប់គ្រង និងការអភិវឌ្ឍប្រកបដោយ និរន្តរភាពអាងទន្លេមេគង្គ៕

The Planning Atlas aims to inform a wide, non-specialist audience about a wide range of land and water related information of the Mekong River Basin. The atlas encourages the reader to explore the different themes and to consider how each might influence the choices that the Mekong River Commission has to make to promote and coordinate sustainable management and development of the Mekong River Basin.

## ការវាយតម្លៃសេណារីយ៉ូអភិវឌ្ឍន៍អាងទន្លេ

## Basin Development Scenario Assessment




ក្នុងអំឡុងពេលនៃកម្មវិធី BDP ២០០៩-២០១១ កម្មវិធីនេះ បានសម្របសម្រួលឱ្យមានការវាយតម្លៃសេដ្ឋកិច្ច សង្គមនិងបរិស្ថាននៃការអភិវឌ្ឍសេណារីយ៉ូអាង។ សេណារីយ៉ូនេះត្រូវបានផ្អែកលើផែនការថ្នាក់ជាតិនៃអាងទន្លេមេគង្គក្រោម (LMB) នៃប្រទេសទាំង៤ (កម្ពុជា ឡាវ ថៃ និងវៀតណាម) បានពិចារណាចំពោះការអភិវឌ្ឍនៅ អាងផ្នែកខាងលើ (ប្រទេសចិន-មីយ៉ាន់ម៉ា)។ ដូច្នេះការវាយតម្លៃសេណារីយ៉ូអាចត្រូវបានចាត់ទុកថាជាការវាយតម្លៃផលប៉ះពាល់កើនបន្តបន្ទាប់ឆ្លងដែននៃផែនការអភិវឌ្ឍន៍របស់ប្រទេស។ លទ្ធផលនេះបានបង្ហាញពីអន្តរកម្មរវាងគោលដៅអភិវឌ្ឍន៍ដែលទាក់ទងទៅនឹងទឹក ថាមពល ស្បៀង បរិស្ថាន ទឹកជំនន់ និងសន្តិសុខ អាកាសធាតុតាមរយៈការធ្វើផែនការថ្នាក់ជាតិដោយមានការសម្របសម្រួល ហើយអត្ថប្រយោជន៍អាចត្រូវទទួលបានសម្រាប់ប្រទេសទាំងអស់។ លទ្ធផលនេះបានបង្ហាញផងដែរនូវការបែងចែកផលប្រយោជន៍ ផលប៉ះពាល់ និងហានិភ័យក្នុងចំណោមបណ្ដាប្រទេសជាសមាជិកនិងវិស័យដែលទាក់ទងទឹកក្នុងប្រទេសទាំងនោះ។

During 2009-2011 the BDP Programme facilitated the economic, social and environmental assessment of basin-wide development scenarios. The scenarios were based on the national plans of the four Lower Mekong Basin (LMB) countries (Cambodia, Lao PDR, Thailand and Viet Nam), taking into account the developments in upper part of the basin (China, Myanmar). Therefore, the scenario assessment can be regarded as a cumulative assessment of the transboundary impacts of the countries' development plans. The results demonstrate the considerable inter-play between the development goals related to water, energy, food, environmental, flood and climate security, and how, through coordinated national planning, benefits can be realized for all countries. The results also indicate the distribution of benefits, impacts and risks among the Member Countries and water related sectors within countries.




ផែនការសកម្មភាពអាងទន្លេ គឺជាឯកសារផែនការសង្ខេបរួមដែលផ្ដល់ជូនអ្នកធ្វើសម្រេចចិត្តគោលនយោបាយ និងសហគមន៍អភិវឌ្ឍជាមួយនឹងទិដ្ឋភាពជាក់ច្បាស់នៃផែនការសកម្ម - ភាពអាងទន្លេ រួមមានផែនការ សកម្មភាពថ្នាក់តំបន់និងផែនការចង្អុលថ្នាក់ជាតិទាំង៤។ ផែនការនេះ ប្រើប្រាស់សម្រាប់អនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេរបស់ MRC ដែលមានគម្រោងថ្នាក់ជាតិ មានសារសំខាន់កម្រិតអាងទាំងមូល និងគម្រោងរួម ដែលអាចនាំឆ្ពោះទៅការវិនិយោគរួមគ្នា៕

Basin Action Plan: An Executive Synthesis to provide policy makers and the broader development community with a concise overview of the Basin Action Plan, comprising the Regional Action Plan and four National Indicative Plans. The Plan is used for implementation of MRC Basin Development Strategy comprises some national projects of basin-wide significance and some joint projects that could lead to joint investments.




សៀវភៅណែនាំការបណ្ដុះបណ្ដាលសម្រាប់គ្រូបង្គោលនៅក្នុងការគ្រប់គ្រងធនធានទឹកចម្រុះក្នុងអាងទន្លេមេគង្គ៕

Training Manual for Training of Trainers in Integrated Water Resources Management in the Mekong Basin.




កិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥៕

The 1995 Mekong Agreement

គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
Cambodia National Mekong Committee

អាគារលេខ ៣៦៤ មហាវិថីព្រះមុនីវង្ស ប្រអប់សំបុត្រលេខ ២២១៤ ភ្នំពេញ៣ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ (៨៥៥)២៣ ២១៦៥១៤/(៨៥៥) ២៣ ២១៨៥០៦

#364, Monivong Blvd.  P.O. Box 2214, Phnom Penh 3, Kingdom of Cambodia

Tel/Fax (855)23 216514/(855) 23 218506

Website: http://www.cnmc.gov.kh